ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ថ្ងៃទី២ ខែមីនា ឆ្នាំ២០២០

# សេចក្តីប្រកាសព័ត៌មាន
## ប្រទេសជប៉ុនផ្តល់ប្រាក់ភាគទានថ្មីដល់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

រដ្ឋាភិបាលជប៉ុនបានប្រកាសផ្តល់ភាគទានថ្មីក្នុងទឹកប្រាក់ចំនួន ៩៦០.០០០ ដុល្លារអាមេរិក ដល់ភាគីអន្តរជាតិនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក)។ ជាមួយប្រាក់ភាគទាននេះ ប្រទេសជប៉ុនបានផ្តល់ជំនួយដល់ភាគីជាតិ និងអន្តរជាតិនៅ អ.វ.ត.ក ជាង ៨៨ លានដុល្លារអាមេរិក ឬ ២៩% នៃប្រាក់ភាគទានសរុបដែលម្ចាស់ជំនួយបានផ្តល់ជូន គិតត្រឹមថ្ងៃទី៣១ ខែមករា ឆ្នាំ២០២០។ ប្រការនេះធ្វើឲ្យប្រទេសជប៉ុនក្លាយជាប្រទេសផ្តល់ជំនួយច្រើនជាងគេដល់ អ.វ.ត.ក ចាប់តាំងពីពេលបង្កើតតុលាការនេះមក។

ឯកឧត្តម **ក្រាញ់ តូនី** ប្រធានការិយាល័យរដ្ឋបាលស្តីទី និងលោក **Knut Rosandhaug** អនុប្រធានការិយាល័យរដ្ឋបាលបានមានប្រសាសន៍នៅក្នុងសេចក្តីថ្លែងការណ៍រួមគ្នាថា៖“អ.វ.ត.ក សូមថ្លែងអំណរគុណដល់ការប្តេជ្ញាចិត្តខ្ពស់របស់ប្រទេសជប៉ុនចំពោះច្បាប់ព្រហ្មទណ្ឌអន្តរជាតិ និង ការស្វែងរកយុត្តិធម៌ជូនប្រជាជនកម្ពុជា ដូចបានបង្ហាញតាមរយៈការបន្តផ្តល់ការគាំទ្រយ៉ាងធំធេងដល់តុលាការនេះ។ ប្រាក់ភាគទានថ្មីនេះមានសារសំខាន់ដល់ អ.វ.ត.ក ក្នុងការបញ្ចប់អាណត្តិការងាររបស់ខ្លួន ដោយពុំមានការអាក់ខាននៅក្នុងកិច្ចដំណើរការនីតិវិធីតុលាការ”។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

លោក នេត្រ ភក្ត្រា
ប្រធានផ្នែកកិច្ចការសាធារណៈ និងជាមន្ត្រីនាំពាក្យ
ទូរស័ព្ទចល័ត៖ +៨៥៥(0)១២ ៤៨៨ ១៥៦
ទូរស័ព្ទលើតុ៖ +៨៥៥(0)២៣ ៨៦១ ៥៦៤
អ៊ីមែល៖ neth.pheaktra@eccc.gov.kh